សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

# សារលិខិត
# របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
# និង ជាប្រធានកិត្តិយសនៃគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
# ក្រោមប្រធានបទ «សកម្មភាពរបស់អ្នក ដើម្បីទីក្រុងស្អាត» នាឱកាសទិវាជាតិទីក្រុងស្អាត
# រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១៤

*- ជនរួមជាតិទាំងអស់ជាទីមេត្រី !*

បច្ចុប្បន្នកម្ពុជាមានសុខសន្តិភាព, ស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់ល្អប្រសើរ និងមានការអភិវឌ្ឍន៍លើគ្រប់វិស័យ ក្នុងនោះ មានវិស័យកសិកម្ម, វិស័យកាត់ដេរ, វិស័យសំណង់ និងវិស័យទេសចរណ៍មានការរីកចម្រើនខ្លាំង ហើយបានរួមចំណែកក្លាយជាសសរទ្រូងទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចកម្ពុជា ។ ដោយឡែក ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធកាន់តែទទួលបាននូវការអភិវឌ្ឍន៍ដ៏ល្អប្រសើរគួរឱ្យកត់សម្គាល់ផងដែរ ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ។ ជាមួយនឹងការរីកចម្រើនឥតឈប់ឈរនេះ រាជរដ្ឋាភិបាលក៏នៅតែបានប្រកាន់ខ្ជាប់នូវគោលនយោបាយនៃការជំរុញនូវកំណើនសេដ្ឋកិច្ចដោយឈរលើការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម, ពិពិធកម្មផលិតកម្ម, បន្តជំរុញការនាំចេញ ទាំងការនាំចេញទៅក្រៅប្រទេស និងការនាំចេញនៅនឹងកន្លែង ព្រមទាំងប្រឹងប្រែងធានាឱ្យបាននូវការបែងចែកផ្លែផ្កាកំណើនឱ្យប្រកបដោយសមធម៌, មានចិរភាព និងក្នុងដំណើរឆ្ពោះទៅរកការអភិវឌ្ឍន៍**សេដ្ឋកិច្ចបៃតង**នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ក្នុងស្មារតីឆ្លើយតបទៅនឹងនិន្នាការអភិវឌ្ឍន៍ថ្មីនេះ កម្ពុជាបានដាក់ចេញនូវយុទ្ធនាការ ***«ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ»*** ដែលជាជម្រើសយុទ្ធសាស្ត្រមួយដ៏សមស្របបំផុត ក្នុងការចូលរួមអភិវឌ្ឍទេសចរណ៍បៃតង និងការធ្វើឱ្យកម្ពុជាឆ្ពោះទៅរកភាពស្អាត និងបៃតង ។ ក្នុងន័យនេះ គ្រប់ទីប្រជុំជន, រមណីយដ្ឋានទេសចរណ៍ទាំងអស់ត្រូវបន្តនូវកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ភាពស្អាត និងភាពបៃតង ដោយត្រូវឈរលើគោលការណ៍**ចិរភាពនៃការអភិវឌ្ឍន៍** ពោលគឺយើងនឹងសម្រេចបាននូវទស្សនាទាន ***«ការអភិវឌ្ឍន៍បច្ចុប្បន្ន គឺសម្រាប់យើងបច្ចុប្បន្នផង និងជំនាន់ក្រោយផង»*** ។

ជាការពិត អ្វីដែលយើងទទួលបាននាពេលនេះ គឺយើងបានចាប់ផ្តើមតាំងពីរាប់ទសវត្សរ៍មកហើយ បើទោះបីអ្វីៗទាំងអស់ត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង ក្នុងរបបប្រល័យពូជសាសន៍កម្ពុជាប្រជាធិបតេយ្យ ដែលបានធ្វើឱ្យប្រជាជនកម្ពុជាត្រូវបាត់បង់អាយុជីវិតអស់រាប់លាននាក់ ហើយកម្ពុជាចាប់ផ្តើមពីចំណុចសូន្យក៏ដោយ ។ ដូច្នេះការបន្តដំណើរឆ្ពោះទៅមុខរបស់កម្ពុជា ក្នុងពេលបច្ចុប្បន្ននេះគឺឈរលើមូលដ្ឋានមួយកាន់រឹងមាំ ធំទូលាយ និងមានភាពប្រាកដប្រជាប្រកបដោយភាពម្ចាស់ការ ។

ក្នុងបរិការណ៍នេះ ជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលបានកំណត់យកថ្ងៃទី ២៧ ខែ កុម្ភៈ ***ប្រារព្ធទិវាជាតិ ទីក្រុងស្អាត*** ដើម្បីជាការក្រើនរំលឹកឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងចលនាប្រឡងប្រណាំង ***ទីក្រុងស្អាត*** ដែលជាផ្នែកមួយនៃ**ព្រះរាជាណាចក្រអច្ឆរិយៈ** ធ្វើឱ្យទីក្រុងយើងកាន់តែស្រស់ស្អាតប្រកបដោយភាពទាក់ទាញ មានបរិស្ថានស្អាត ឆ្ពោះទៅរកគោលដៅ ***«កម្ពុជាស្អាត កម្ពុជាបៃតង»*** ។ ជាក់ស្តែងឆ្នាំនេះ យើងត្រូវប្រារព្ធខួបលើកទី ២ ទិវាជាតិទីក្រុងស្អាត ក្រោមប្រធានបទ ***«សកម្មភាពរបស់អ្នក ដើម្បីទីក្រុងស្អាត»*** ។ ប្រធានបទនេះមានអត្ថន័យរំលេចឱ្យឃើញពីការបន្តគោលគំនិត ខ្លឹមសារ និងទស្សនវិស័យរបស់យើងទាំងអស់គ្នា ក្នុងការ ***«រួមគិត រួមធ្វើ រួមទទួលខុសត្រូវ»*** ក្នុងការធ្វើឱ្យ**កម្ពុជាស្អាត កម្ពុជាបៃតង** ។ ទាំងអស់នេះសបញ្ជាក់ឱ្យឃើញថា គ្រប់សកម្មភាពទាំងអស់របស់ប្រជាជន សិស្ស- និស្សិត ភ្ញៀវទេសចរជាតិ អន្តរជាតិ ពិតជាមានសារៈសំខាន់ និងចាំបាច់ជួយទ្រទ្រង់ដល់**ចលនាប្រឡងប្រណាំងទីក្រុងស្អាត**ឱ្យទទួលបានជោគជ័យ និងនាំឆ្ពោះទៅរកការអភិវឌ្ឍ **កម្ពុជាស្អាត កម្ពុជាបៃតង** សម្រាប់យើងទាំងអស់គ្នានាពេលបច្ចុប្បន្ន និងកូនចៅយើងជំនាន់ក្រោយៗទៅអនាគតទៀត ។

ដើម្បីចូលរួមដល់ការប្រឡងប្រណាំងទីក្រុងស្អាត រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធនាការមួយចំនួន ដូចជា យុទ្ធនាការ ***«យុវជន និងទីក្រុងស្អាត»*** យុទ្ធនាការ ***«ទីក្រុងស្អាត ទីក្រុងដែលគ្មានសំរាមជាថង់ប្លាស្ទិក ហើរតាមខ្យល់»*** យុទ្ធនាការ**សម្អាតឆ្នេរសមុទ្រ** ក្រោមប្រធានបទ ***«ស្រឡាញ់ផ្ទៃសមុទ្រខៀវស្រងាត់ ទីក្រុងបៃតង»*** និងយុទ្ធនាការដាំដើមឈើក្រោមប្រធានបទ ***«ដាំដើមឈើផ្តើមចេញពីអ្នក»*** ដែលយុទ្ធនាការទាំងនេះ អាចទទួលជោគជ័យទៅបានទាមទារឱ្យមានការចូលរួមពីប្រជាជនពីគ្រប់មជ្ឈដ្ឋាន វិស័យសាធារណៈ វិស័យឯកជន និងគ្រប់ភាគីពាក់ព័ន្ធ ដោយផ្តោតសំខាន់លើការធ្វើសកម្មភាពនានាឱ្យក្លាយជាលំនៅដ្ឋានស្អាត ស្ថាប័នស្អាត កន្លែងធ្វើការស្អាត វត្តអារាមស្អាត រោងចក្រស្អាត ជាដើម ។ ឆ្លៀតឱកាសនេះ ខ្ញុំសូមកោតសរសើរដល់គ្រប់ទីក្រុងបេក្ខភាព និងប្រជាជនគ្រប់រូប ដែលបានគាំទ្រ និងចូលរួមដល់យុទ្ធនាការប្រឡងប្រណាំងទីក្រុងស្អាតនាពេលកន្លងមក ។ ជាមួយនេះ ខ្ញុំសូមអំពាវនាវឱ្យគ្រប់ក្រុង- ខណ្ឌ បេក្ខភាព ក៏ដូចជាគ្រប់ក្រុមហ៊ុន សហគ្រាស រោងចក្រ អង្គការជាតិ និងអន្តជាតិ យុវជន- យុវនារី សិស្សានុសិស្ស ព្រះសង្ឃ បងប្អូនប្រជាជនគ្រប់រូបបន្តសហការចូលរួមគាំទ្រ និងឧបត្ថម្ភយុទ្ធនាការទាំងនោះ ដើម្បីបានជាប្រយោជន៍សម្រាប់យើងទាំងអស់គ្នា ។

ក្នុងស្មារតីនេះ ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមដាក់ចេញនូវយុទ្ធនាការបន្ថែមទៀត ដូចខាងក្រោម ÷

***ទី១.*** រៀបចំឱ្យមាន**សកម្មជនទីក្រុងស្អាត** នៅតាមកន្លែងធ្វើការ ស្ថាប័ន សាលារៀន គ្រឹះស្ថានសិក្សា វត្តអារាម ផ្សារ រោងចក្រ សហគ្រាស បុរី ជាដើម សំដៅធ្វើឱ្យកន្លែងទាំងនោះ ប្រកបដោយ**ភាពស្អាត** និង**បៃតង** គ្រប់រដូវកាល គ្រប់ពេលវេលា ។ ទន្ទឹមនេះ បន្តជំរុញលើកទឹកចិត្តយុទ្ធនាការ ***«ទេសចរម្នាក់ ដើមឈើមួយដើម»*** និង ***«យុវជនម្នាក់ ដើមឈើមួយដើម»*** និង ***«គូស្រករមួយគូ ដើមឈើពីរដើម»*** ជាដើម ។

***ទី២.*** ស្របពេលដែលរាជរដ្ឋាភិបាលនឹងដាក់ចេញនូវ**មូលនិធិអនាម័យបរិស្ថាន** ត្រូវយកចិត្តទុកដាក់រៀបចំឱ្យមាន**សង្កាត់គំរូ** នៅតាមទីក្រុង, ទីប្រជុំជនទីមួយៗ និងជំរុញលើកទឹកចិត្តឱ្យមានការរៀបចំបង្គន់អនាម័យសាធារណៈស្របតាមស្តង់ដាររបស់អាស៊ានឱ្យបានល្អនៅតាមទីសាធារណៈ និងរមណីយដ្ឋានទេសចរណ៍គ្រប់រាជធានី- ខេត្ត ។

ទន្ទឹមគ្នានេះ ឆ្លៀតក្នុងឱកាសទិវាដ៏វិសេសវិសាលនេះ ខ្ញុំសូមអំពាវនាវដល់ក្រសួង- ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ បងប្អូនជនរួមជាតិទាំងអស់ អង្គការសង្គមស៊ីវិល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ សូមចូលរួមឱ្យបានផុសផុលប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចំពោះយុទ្ធនាការនានាដែលយើងបាន

ដាក់ចេញ ។ ក្នុងនោះប្រធានបទ ***«សកម្មភាពរបស់អ្នក ដើម្បីទីក្រុងស្អាត»*** បានឆ្លុះបញ្ចាំងយ៉ាងច្បាស់ថា ដើម្បីធ្វើឱ្យទីក្រុងរបស់យើងកាន់តែស្រស់ស្អាតស័ក្តិសមជា **«ទីក្រុងស្អាត** និង**បៃតង»** គឺផ្តើមចេញពីយើងម្នាក់ៗ ។ ជារួម កិច្ចការទាំងអស់នេះជាការត្រៀមខ្លួនក្នុងការចូលរួមការប្រឡងប្រណាំងទីក្រុងស្អាតអាស៊ាននៅឆ្នាំ ២០១៥ ខាងមុខនេះផងដែរ ដោយមាន**ចលនាប្រឡងប្រណាំងទីក្រុងស្អាត** ស្របតាម**ស្តង់ដារទីក្រុងទេសចរណ៍ស្អាតអាស៊ាន** ដែលត្រូវបានអនុម័តដោយរដ្ឋមន្ត្រីទេសចរណ៍អាស៊ាន នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ នាពេលកន្លងមកនេះ ។

ក្នុងន័យទាំងអស់នេះ ខ្ញុំមានសង្ឃឹមយ៉ាងមុតមាំថា ការប្រឡងប្រណាំងទីក្រុងស្អាតនឹងក្លាយជាកាលានុវត្តភាពដ៏ប្រសើរថ្មីមួយទៀតសម្រាប់កម្ពុជា ក្នុងការធ្វើឱ្យទីក្រុងរបស់ខ្លួនក្លាយជាគោលដៅស្អាត និងបៃតង ប្រកបដោយគុណភាពដែលជាកត្តាចូលរួមចំណែកដល់ការកាត់បន្ថយបញ្ហាការផ្លាស់ប្តូរអាកាសធាតុ ពិសេសចូលរួមចំណែកធ្វើឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍសហស្សវត្សរ៍របស់អង្គការសហប្រជាជាតិ និងរបស់កម្ពុជា ព្រមទាំងបង្កើនស្មារតីស្រឡាញ់ជាតិមាតុភូមិ សាមគ្គីភាព និងមិត្តភាពផងដែរ ។ ចំពោះមុខនេះ ខ្ញុំក៏សូមជូនពរឱ្យ ***ការប្រឡងប្រណាំងទីក្រុងស្អាត*** និង ***ទិវាជាតិទីក្រុងស្អាត***ប្រព្រឹត្តទៅប្រកបដោយជោគជ័យជានិច្ចនិរន្តរ៍ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៤*

**ហ៊ុន សែន**